# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពីសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន
# គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ឆ្នាំ ២០០៣-២០០៤

## ១.សេចក្តីផ្តើម

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (**គ.ទ.ក**) គឺជាយន្តការគតិយុត្តមួយ សំរាប់ គ្រប់គ្រងដំណើរការនៃការធានា និងលើកកំពស់គុណភាពអប់រំឧត្តមសិក្សានៅកម្ពុជា ឱ្យមាន ប្រសិទ្ធិភាព ខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ ។ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាមាន អគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានតួនាទីយ៉ាងសំខាន់ ក្នុងការបំពេញបេសកកម្ម និង អនុវត្តរាល់ភារកិច្ចទាំងឡាយ របស់គណៈកម្មាធិការនេះ ។ ដើម្បីបំពេញបេសកកម្ម និង អនុវត្តរាល់ ភារកិច្ចទាំងនោះ អគ្គលេខាធិការដ្ឋានបាន ធ្វើកិច្ចសហការ និងទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយគ្រប់គ្រឹះ ស្ថានឧត្តមសិក្សានានាក្នុងប្រទេស ក្នុងការកសាងបទដ្ឋានគតិយុត្តិនានា ដើម្បីពង្រឹងគុណភាពអប់រំ ឧត្តមសិក្សា បានធ្វើកិច្ចសហប្រត្តិបតិការជាមួយ ធនាគារពិភពលោក ដើម្បីស្វែងរកជំនួយបច្ចេកទេស និង ហិរញ្ញវត្ថុ និងបានធ្វើកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសមួយចំនួនក្នុងតំបន់ ដូចជា ឥណ្ឌា ថៃ ម៉ាឡេស៊ី ដើម្បីប្រមូលនូវបទពិសោធន៍ល្អៗ សំរាប់រៀបចំស្តង់ដារទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា កម្ពុជា ឱ្យមានលក្ខណៈសមស្របជាមួយ បណ្តាប្រទេសទាំងនោះ និងអាច អនុវត្តបាននៅក្នុងបរិបទ នៃប្រទេសកម្ពុជា ។

បច្ចុប្បន្ន យើងមានគ្រឹះស្ថានឧត្តមសិក្សាចំនួន ៣៧ ក្នុងនោះ ១០ ជាគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និង ២៧ ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ។ ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាទាំង ៣៧ នោះ មានសាកល វិទ្យាល័យចំនួន ២១ ( រដ្ឋ ៧ និងឯកជន ១៤) និងមាន វិទ្យាស្ថានចំនួន ១៦ ( រដ្ឋ៣ និង ឯកជន ១៣ ) ។ ក្រៅពីនេះមានគ្រឹះស្ថាន ឧត្តមសិក្សាមួយចំនួន ដែលបណ្តុះបណ្តាល បច្ចេកទេស និង វិជ្ជាជីវៈ ថ្នាក់បរិញ្ញាប័ត្រ និង បរិញ្ញាប័ត្រ ជាន់ខ្ពស់ ។

## ២. សកម្មភាពការងារ

អគ្គលេខាធិការដ្ឋានបានចាប់ផ្តើមការងារខ្លួនតាំងពីបាតដៃទទេរ នៅខែ មិថុនា ឆ្នាំ ២០០៤ ប៉ុន្តែដោយមានការគាំទ្រយ៉ាងខ្លាំងពី រាជរដ្ឋាភិបាល និងពីសំណាក់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី

ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទាំងផ្នែកហិរញ្ញវត្ថុ សំភារៈ និង ស្មារតី ក្នុងរយៈពេលជាងមួយឆ្នាំកន្លងមក អគ្គលេខាធិការដ្ឋាន បានសំរេចបាននូវ សមទ្ធិផលជាមូលដ្ឋានមួយចំនួនដូចខាងក្រោម -:

## ២.១.អំពី ការងាររៀបចំស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំ

ក- បានធ្វើអង្កេត (Survey) ស្ទាបស្ទង់ស្ថានភាពពិតនៃគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ដើម្បីជាមូលដ្ឋានក្នុងការរៀបចំស្តង់ដារអប្បរមា ។ គ្រឹះស្ថានឧត្តមសិក្សាស្ទើរទាំងអស់បានឆ្លើយ និងបញ្ជូនត្រឡប់វិញនូវតារាងសំណួររបស់អគ្គលេខាធិការដ្ឋាន ។

ខ- បានរៀបចំសេចក្តីសំរេចស្តីពីលក្ខខណ្ឌនៃការចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ។ **គឧក** បានចេញសេចក្តីសំរេច លេខ ០២ / ០៤ គ.ទ.ក. សសរ ចុះថ្ងៃ **២២** មីនា ឆ្នាំ២០០៤ និងដាក់អោយគ្រប់គ្រឹះស្ថានឧត្តមសិក្សាដើម្បីអនុវត្ត ។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋានកំពុងរៀបចំសេចក្តីណែនាំលំអិត សំរាប់ការអនុវត្តសេចក្តីសំរេចនេះ ។

គ- បានរៀបចំសេចក្តីសំរេចស្តីពីការសិក្សាជាប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីតនៅតាមគ្រឹះស្ថានឧត្តមសិក្សា ។ **គឧក** បានចេញសេចក្តីសំរេច លេខ ០៤ / ០៤ គ.ទ.ក. សសរ ចុះថ្ងៃ **១៩** វិច្ឆកា ឆ្នាំ ២០០៤ និងបានដាក់អោយគ្រប់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីអនុវត្ត ។

ឃ- កំពុងរៀបចំសេចក្តីព្រាង បទដ្ឋានចំនួន ០៣ ទៀត ដូចខាងក្រោម :

ឃ.១- សេចក្តីសំរេច ស្តីពី លក្ខណៈវិនិច្ឆ័យ ស្តីពី ការជ្រើសរើសអ្នកវាយតំលៃ (Assessor)

ឃ.២-សេចក្តីណែនាំលំអិតស្តីពីដំណើរការរៀបចំថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់គ្រឹះស្ថានឧត្តមសិក្សា

ឃ.៣- សេចក្តីណែនាំ ស្តីពី ដំណើរការវាយតំលៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់អ្នកវាយតំលៃ

## ២.២. អំពី ការងារកិច្ចសហប្រតិបត្តិការ និងពិតមាន

ក- បានសហការជាមួយធនាគារពិភពលោក (The World Bank) ដើម្បីពង្រឹងផ្នែកបច្ចេកទេសរបស់ **គឧក** ជាពិសេសអគ្គលេខាធិការដ្ឋាន ។ បានជួបប្រជុំការងារជាច្រើនលើក ក្នុងឆ្នាំ២០០៤ រវាងអ្នកជំនាញ (Consultant) របស់ធនាគារពិភពលោក ក្រសួងអប់រំ យុវជន និងកីឡា និង អគ្គលេខាធិការដ្ឋាននៃ **គឧក** ។

ខ- បានសហការជាមួយរដ្ឋាភិបាលនៃប្រទេសជាមិត្តចំនួនបីក្នុងតំបន់អាស៊ីប៉ាស៊ីភិច ក្នុងនោះមាន ប្រទេសឥណ្ឌា ប្រទេសថៃ ក្នុងការធ្វើទស្សនកិច្ចសិក្សា (Study visit) ដកស្រង់បទពិសោធន៍ និងបានធ្វើកម្មសិក្សារយៈពេលខ្លី(Intenship Program) នៅប្រទេសម៉ាឡេស៊ីលើផ្នែក ធានា និង ទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ។

គ- បានសហការជាមួយស្ថានទូតមួយចំនួនប្រចាំនៅទីក្រុងភ្នំពេញ ។ ស្ថានទូតសហរដ្ឋអាមេរិក បានផ្ដល់វាគ្មិនម្នាក់ជាសាស្ត្រាចារ្យនៅ Eastern Illinois University មកធ្វើសិក្ខាសាលា អំពីការ សិក្សាជាប្រព័ន្ធក្រេឌីតនិងការផ្ទេរក្រេឌីត ។ ស្ថានទូតសហរដ្ឋអាមេរិចក៏បានបន្តជួយពង្រឹងអគ្គលេខាធិការដ្ឋានផងដែរ តាមរយៈការផ្ដល់អ្នកជំនាញការជាន់ខ្ពស់ហ្វ៊ុលប្រៃ (Fulbright Senior Specialist) សំរាប់រយៈពេលប្រាំមួយសប្ដាហ៍ ដើម្បីរៀបចំស្តង់ដារអបប្បរមាលំអិត និងសិក្ខាសាលា។ អ្នកជំនាញការនេះនឹង មកដល់កម្ពុជាក្នុងខែកុម្ភៈឆ្នាំ២០០៥ខាងមុខនេះ ។

ជាមួយគ្នានេះដែរ អគ្គលេខាធិការដ្ឋាន កំពុងបន្តធ្វើការជាមួយស្ថានទូតប្រទេសអូស្ត្រាលី ដើម្បីទទួលយកអ្នកជំនាញការពី ABV (Australian Business Volunteer) ក្នុងការជួយរៀបចំប្រព័ន្ធធានាគុណភាពអប់រំ នៅកម្ពុជា ។

ឃ- បានសហការជាមួយបណ្ដាញគុណភាពអាស៊ីប៉ាស៊ីភិច (Asia Pacific Quality Network - APQN ) ដើម្បីចូលជាសមាជិក និងទទួលការឧបត្ថមផ្នែកបច្ចេកទេស និងពតិមាន ។ ជាលទ្ធផលអគ្គលេខាធិការដ្ឋាននឹងបញ្ជូនមន្ត្រីមួយរូបទៅចូលរួមប្រជុំនៅទីក្រុងហុងកុង នាចុងខែមករា ឆ្នាំ២០០៥ ខាងមុខនេះ ។

**២.៣.ការផ្គត់ផ្គង់សំភារៈ**

- បានរៀបចំបន្ទប់បានចំនួន១០ ដែលក្នុងនោះ នៅទីស្ដីការគណៈរដ្ឋមន្ត្រីមាន០៣បន្ទប់ នៅCDC មាន ០៧ បន្ទប់ ។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋានត្រូវបានផ្លាស់ទីតាំង ពីទីស្ដីការគណៈរដ្ឋមន្ត្រី និង CDCទៅអតីតអាគារខេមរៈជាន់ ទី៣ ដែលមាន ១៤ បន្ទប់។ ចំនួនបន្ទប់នេះ សមរម្យល្មមសំរាប់អគ្គលេខាធិការដ្ឋាន ដែលមាន០៣ នាយកដ្ឋាន និង០៦ការិយាល័យ ។ ហើយអាចដក មួយបន្ទប់សំរាប់ធ្វើបន្ទប់ប្រជុំ និងមួយបន្ទប់ទៀត សំរាប់ជំនាញការបរទេស ដែលនឹងមកជួយធ្វើការយើង នៅពេលខាងមុខនេះ ផងដែរ។

ទោះបីយើងមានបន្ទប់គ្រប់គ្រាន់ក្ដី ក៏យើងនៅខ្វះសំភារៈចាំបាច់មួយចំនួនដូចជា ម៉ាសុីន Computer ម៉ាស៊ីន Printer Fax ម៉ាស៊ីនថតចំលង ទូរដាក់ឯកសារ តុ កៅអី ជាដើម ។ ម្យ៉ាងទៀតកន្លងមកយើងប្រើប្រាស់សំភារៈមួយចំនួន ដូចជា តុ កៅអី ទូរដាក់ឯកសារ របស់ CDC តែក្រោយពីយើងផ្លាស់មកកន្លែងថ្មី សំភារៈទាំងនោះត្រូវបានខាង CDC គេដកយកវិញ។

- បានធ្វើបញ្ជីសារពើភ័ណ្ឌកត់ត្រាទ្រព្យសម្បត្តិអគ្គលេខាធិការដ្ឋាន ។សព្វថ្ងៃ អគ្គលេខាធិការដ្ឋានមានសំភារៈ ប្រើប្រាស់មួយចំនួនដូចខាងក្រោម÷

| | |
|---|---|
| ១- Computer / | ចំនួន ៤ គ្រឿង ថ្មី និង ចាស់ ចំនួន ៥ គ្រឿង |
| ២- Printer | ចំនួន ៣ គ្រឿង |

៣- ម៉ាស៊ីនថតចំលងចាស់                    ចំនួន ១ គ្រឿង

ក្នុងដំណាក់កាលដំបូង ដើម្បីដោះស្រាយបញ្ហាខ្វះខាតមន្ត្រីរបស់យើងមួយចំនួនបានស្ម័គ្រចិត្តទិញសំភារៈ និង ចេញថវិកាជួសជុលសំភារៈដោយខ្លួនឯង ដើម្បីរៀបចំបន្ទប់អោយអាចធ្វើការងារបាន។ ការចំណាយថវិការផ្ទាល់ខ្លួនអស់ ៦៤៨ ដុល្លា ។

**២.៤. អំពីបុគ្គលិក**

សព្វថ្ងៃអគ្គលេខាធិការដ្ឋានមានមន្ត្រី ២៤រូប ក្នុងនោះ មន្ត្រីមានក្របខ័ណ្ឌរដ្ឋ ចំនួន ១៦ រូប និង បុគ្គលិកជាប់កិច្ចសន្យាចំនួន ០៨ រូប។

**មន្ត្រីក្របខ័ណ្ឌរដ្ឋ ចំនួន ១៦ រូប** ក្នុងនោះមាន :

- បណ្ឌិតរដ្ឋ ចំនួន ០១ រូប
- បណ្ឌិត ចំនួន ០២ រូប
- អនុបណ្ឌិត ចំនួន ០៧ រូប
- បរិញ្ញាប័ត្រ + សញ្ញាប័ត្រមន្ត្រីជាន់ខ្ពស់សាលាភូមិន្ទរដ្ឋបាល ចំនួន ០១ រូប
- បរិញ្ញាប័ត្រ + សញ្ញាប័ត្រមន្ត្រីមធ្យមសាលាភូមិន្ទរដ្ឋបាល ចំនួន ០១ រូប
- សញ្ញាប័ត្រវេជ្ជបណ្ឌិត ចំនួន ០១ រូប
- បរិញ្ញាប័ត្រ ០២ រូប
- សញ្ញាប័ត្រទុតិយភូមិ ចំនួន ០១ រូប

**មន្ត្រីកិច្ចសន្យាចំនួន ០៨ រូប** ក្នុងនោះមាន :

- អនុបណ្ឌិត ចំនួន ០២ រូប
- បរិញ្ញាប័ត្រ ចំនួន ០៥ រូប
- បរិញ្ញាប័ត្ររងចំនួន ០១ រូប

**២.៥. អំពីបទដ្ឋានគតិយុត្តិ**

***ក. លិខិតបទដ្ឋានគតិយុត្តិជាធរមាន ដែលពាក់ព័ន្ធនឹង គ.ទ.ក រួមមាន:***

១- ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

២- អនុក្រឹត្យលេខ ៤៦/អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

៣- សេចក្ដីសំរេចលេខ ០១/០៣ គ.ទ.ក ស.ស.រ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ។ របស់នាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

៤- សេចក្ដីសំរេចលេខ ០២/០៤ គ.ទ.ក ស.ស.រ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៤ ស្ដីពីលក្ខខណ្ឌសំរាប់ការចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានឧត្តមសិក្សា

៥- សេចក្ដីសំរេច លេខ០៤/០៤ គ.ទ.ក ស.ស.រ ចុះថ្ងៃទី ១៩ ខែ វិច្ឆកា ឆ្នាំ ២០០៤ ស្ដីពីកម្មវិធីសិក្សាជាប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីត នៅឧត្តមសិក្សា

៦- បទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន

### ខ. លិខិតបទដ្ឋានដែលបានព្រាងរួច និង កំពុងព្រៀង ហើយមិនទាន់ចូលជាធរមាន

១- បទបញ្ជាផ្ទៃក្នុង គ.ទ.ក

២- សេចក្ដីសំរេច ស្ដីពី លក្ខណៈវិនិច្ឆ័យ ស្ដីពី ការជ្រើសរើសអ្នកវាយតំលៃ (Assessor )

៣- សេចក្ដីណែនាំលំអិតស្ដីពីដំណើរការរៀបចំថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់គ្រឹះស្ថាន-ឧត្តមសិក្សា

៤- សេចក្ដីណែនាំ ស្ដីពី ដំណើរការវាយតំលៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់អ្នកវាយតំលៃ

## ២.៦.ទិសដៅការងារខាងមុខ

ផ្អែកលើផែនការប្រាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន កិច្ចការបន្តដែលត្រូវធ្វើក្នុងឆ្នាំ២០០៥ ខាងមុខមានដូចខាងក្រោម ÷

- បញ្ចប់សេចក្ដីព្រាងបទដ្ឋានមួយចំនួនដែលកំពុងព្រៀងសព្វថ្ងៃ រួមមានៈ
  + សេចក្ដីសំរេច ស្ដីពី លក្ខណៈវិនិច្ឆ័យ ស្ដីពី ការជ្រើសរើសអ្នកវាយតំលៃ (Assessor )
  + សេចក្ដីណែនាំលំអិតស្ដីពីដំណើរការរៀបចំថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់គ្រឹះស្ថានឧត្តមសិក្សា
  + សេចក្ដីណែនាំ ស្ដីពី ដំណើរការវាយតំលៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់អ្នកវាយតំលៃ
- រៀបចំសិក្ខាសាលាអប្បរមា លំអិតដែលជាមូលដ្ឋានគ្រឹះសំរាប់ផ្ដល់ការទទួលស្គាល់គុណភាពអប់រំ ដល់ គ្រប់គ្រឹះស្ថានឧត្តមសិក្សា ជាមួយអ្នកជំនាញការ របស់ Fulbright សហរដ្ឋអាមេរិក ។
- កំណត់នីតិវិធីក្នុងការផ្ដល់ការទទួលស្គាល់គុណភាពអប់រំ ដល់គ្រឹះស្ថានឧត្តមសិក្សា
- កំណត់គោលការណ៍សំរាប់ផ្ដល់ការយល់ព្រមដល់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការកំណត់លក្ខខណ្ឌសំរាប់និស្សិតវ័យចំណាស់ និងនិស្សិតមកពីគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស ឬ គ្រឹះស្ថានសិក្សាក្រោយមធ្យមសិក្សាទុតិយភូមិ ។

- បន្តកិច្ចសហប្រតិបត្តិការជាតិ និង អន្តរជាតិដើម្បីស្វែងរកជំនួយបច្ចេកទេស និង ហិរញ្ញវត្ថុ
- បន្តដោះស្រាយការងារជាន់គ្នាមួយចំនួន ជាមួយក្រសួងអប់រំ យុវជន និងកីឡា
- ត្រៀមរៀបចំ បំពាក់សំភារៈបន្ថែមអោយបាន គ្រប់គ្រាន់ដូចជា តុ, កៅអី, ទូរឯកសារ, ម៉ាស៊ីនថតចំលង, ម៉ាស៊ីន Printer, ម៉ាស៊ីន Fax, បណ្តាញទូរស័ព្ទ និង Internet ព្រមទាំងបណ្តាញ Network ។
- បង្កើតគេហទំព័រ **www.acc.gov.kh** របស់គ.ទ.ក ដើម្បីបង្ហោះតាមប្រព័ន្ធ Internet
- ជ្រើសរើសបុគ្គលិកដែលមានសញ្ញាប័ត្រខ្ពស់មួយចំនួនបន្ថែមទៀត។
- រៀបចំធ្វើគំរោងចំណាយប្រចាំឆ្នាំ២០០៥ របស់អគ្គលេខាធិការដ្ឋាន គ.ទ.ក ។

## ៣.សេចក្តីសន្និដ្ឋាន

- អគ្គលេខាធិការដ្ឋានត្រូវបានបង្កើតឡើង នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ដែលរហូតមកទល់នឹងពេលនេះ ទើបតែមានរយៈពេលតែជាង ១ឆ្នាំ ប៉ុណ្ណោះ ។ ថ្វីត្បិត តែរយៈពេលដ៏ខ្លីប៉ុន្តែអគ្គលេខាធិការដ្ឋានបានសំរេចនូវលទ្ធផលការងារសំខាន់ៗមួយចំនួន គួរអោយកត់សំគាល់។

- ក្នុងពេលបច្ចុប្បន្ននេះ អគ្គលេខាធិការដ្ឋានស្ថិតនៅក្នុងដំណាក់កាលកសាងបទដ្ឋានគតិយុត្តិនានាដែលជាឧបករណ៍ ឬ ជាខ្នាត សំរាប់ការវាយតំលៃ និងផ្តល់ការទទួលស្គាល់គុណភាពអប់រំ ដល់គ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ។

- ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់របស់ អគ្គលេខាធិការដ្ឋាន បានខិតខំយកចិត្តទុកបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវលើភារកិច្ចរបស់ខ្លួន ដើម្បីជំរុញល្បឿនការងារ អោយបានឆាប់រហ័សនិងប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែការខ្វះខាតសំភារៈមួយចំនួន ដូចជា : Computer Printer ម៉ាស៊ីនថតចំលង និងសំភារៈការិយាល័យមួយចំនួនទៀត ក៏ជាមូលហេតុធ្វើអោយការងារយឺតយ៉ាវ ផងដែរ។ ទន្ទឹមនឹងនោះដែរ យើងក៏ត្រូវការចាំបាច់អ្នកជំនាញការបរទេសផងដែរ ដើម្បីជួយការងារបច្ចេកទេស ព្រោះនេះ ជាការងារមួយថ្មីណាស់សំរាប់យើងទាំងអស់គ្នា។

- ដោយសារតែមានការគាំទ្រយ៉ាងខ្លាំងពីរាជរដ្ឋាភិបាល និងពីសំណាក់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងការខិតខំប្រែង របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់របស់អគ្គលេខាធិការដ្ឋាន ក្នុងរយៈពេលជាងមួយឆ្នាំកន្លងមក ធនាគារពិភពលោក ដែលបានផ្អាកការគាំទ្រលើ គ.ទ.ក មួយរយៈមកនោះ ឥឡូវបានចាប់ផ្តើមគាំទ្រឡើងវិញ ដោយគ្រោងនឹងផ្តល់ជំនួយ (Grant) មួយចំនួនដល់ គ.ទ.ក នាពេលខាងមុខ ដើម្បីពង្រឹងសមត្ថភាពស្ថាប័នដ៏ថ្មីមួយនេះ។ ទន្ទឹមនឹងនោះ ក៏មានប្រទេសមួយចំនួន ដូចជា សហរដ្ឋអាមេរិក អូស្ត្រាលី ម៉ាឡេស៊ី ថៃ ឥណ្ឌា បានផ្តោត

ការចាប់អារម្មណ៍លើ គ.ទ.ក ផងដែរ ហើយគេគ្រោងផ្តល់អ្នកជំនាញការមកជួយ បើសិនជាយើងត្រូវការ ។